# គណៈទន្តពេទ្យកម្ពុជា

## ១. សេចក្តីផ្តើម

ជាទូទៅទន្តពេទ្យមានសារៈសំខាន់ណាស់ក្នុងការជួយសម្រាល និងដោះស្រាយបញ្ហាទាំងឡាយ ទាក់ទិន្ននឹងសុខភាពមាត់-ធ្មេញ ការទំពាអាហារ និងសម្រស់ផ្ទៃមុខរបស់មនុស្សគ្រប់រូបមិនអាចខ្វះបាន ។ ដើម្បីសម្រេចគោលដៅនេះ តម្រូវឲ្យទន្តពេទ្យទាំងអស់ប្រតិបត្តិវិជ្ជាជីវៈដោយផ្អែកលើចំណេះដឹងវិទ្យាសាស្ត្រ និងក្រមសីលធម៌វិជ្ជាជីវៈ ។ ក្នុងន័យនេះ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាព និងការពង្រឹងសមត្ថភាពវិជ្ជាជីវៈជាការចាំបាច់ ដើម្បីជាទំនុកចិត្តដល់អ្នកមកទទួលសេវាកម្មទាំងក្នុង និងក្រៅប្រទេស អភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

## ២.មូលហេតុ និងគោលបំណងនៃការបង្កើតគណៈទន្តពេទ្យកម្ពុជា

ស្របតាមព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ស្របនឹងនិន្នាការសង្គមសេដ្ឋកិច្ចសហសវត្សថ្មីនៃចរន្តសមាហរណកម្មក្នុងតំបន់ និងសកលភាវូបនីយកម្ម និងដើម្បីគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធិភាព គណៈទន្តពេទ្យកម្ពុជា ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៣៩៦ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ។

គណៈទន្តពេទ្យកម្ពុជាបង្កើតឡើង ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងទន្តពេទ្យទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណង៖

- លើកកម្ពស់សីលធម៌របស់ទន្តពេទ្យ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរ និងភាពសុច្ចរិតក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្ររបស់ទន្តពេទ្យ
- លើកកម្ពស់គុណភាព និងប្រសិទ្ធិភាពនៃការព្យាបាលរបស់ទន្តពេទ្យ
- ជម្រុញវិស័យទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ឲ្យមានភាពជឿនលឿនដូចអារិយប្រទេស តាមរយៈការប្រមូលផ្តុំ គ្រប់គ្រង និងអភិវឌ្ឍវិជ្ជាជីវៈ។

## ៣.ចក្ខុវិស័យ

គណៈទន្តពេទ្យកម្ពុជា ជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលត្រូវបានបង្កើតឡើង ដើម្បីប្រមូលផ្តុំ គ្រប់គ្រងទន្តពេទ្យទូទាំងប្រទេស ក្នុងការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ ឲ្យមានស្តង់ដារជាតិ និងអន្តរជាតិ ជំរុញការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ។

## ៤.បេសកកម្មរបស់គណៈទន្តពេទ្យកម្ពុជា

គណៈទន្តពេទ្យកម្ពុជា ជាអង្គការវិជ្ជាជីវៈតែមួយគត់ដែលមានមុខងារៈ

- ឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិតយុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រឲ្យបានគង់វង្ស និងមានប្រសិទ្ធភាព។
- ឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ទន្តពេទ្យ។
- ជានាការពារកិត្តិយស និងឥស្សរភាពរបស់វិជ្ជាជីវៈទន្តសាស្ត្រ។
- ដាក់វិន័យដល់ទន្តពេទ្យដែលប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈ

## ៥.សារៈប្រយោជន៍សមាជិកគណៈទន្តពេទ្យកម្ពុជា

- ទទួលបានការការពារតាមរយៈក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី-ខេត្ត ភូមិភាគ ជាតិ។
- ទទួលបានសិទ្ធិស្របច្បាប់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា។
- ទទួលបានសិទ្ធិស្របច្បាប់ក្នុងការស្នើសុំលិខិតអនុញ្ញាតបើកបន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់-ធ្មេញ ឬគ្លីនិកពិនិត្យព្យាបាលជម្ងឺមាត់-ធ្មេញនៅព្រះរាជាណាចក្រកម្ពុជា។
- ទទួលបានការអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈ។